**គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (គ.ប.ស.យ)**

Committee For Free And Fair Elections In Cambodia (COMFREL)

ខុមហ្វ្រែល COMFREL

ទីស្នាក់ការកណ្តាល ផ្ទះលេខ ១៣៨ ផ្លូវ ១២២ សង្កាត់ទឹកល្អក់ ១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

Central Office: #138, St. 122, Teuk Laak I, Tuol Kork, Phnom Penh, CAMBODIA.

P.O. Box 1145, Tel: (855) 23 884 150/12 942 019, Fax: (855) 23 883 750 E-mail: comfrel@online.com.kh, comfrel@comfrel.org or comfreladmin@online.com.kh, Site : www.comfrel.org



**គណៈកម្មាធិការនាយក**

BOARD OF DIRECTORS

1. លោក **ធុន សារាយ** Mr. THUN Saray ប្រធានគណៈកម្មាធិការនាយក និងជាប្រធាន ADHOC
2. លោក **សុក សំអឿន** Mr. SOK Sam Oeun អនុប្រធានគណៈកម្មាធិការនាយក និងជានាយក CDP
3. លោក **យឹម ប៉ូ** Mr. YIM Po អគ្គហេរញ្ញិក និងជានាយក CCPCR
4. អ្នកស្រី **ស៊ុន ចាន់សែន** Mrs. SUN Chansen សមាជិកា និងជាប្រធាន KYA
5. លោក **យង់ គិមអេង** Mr. YONG Kim Eng សមាជិក និងជានាយក PDP-Center
6. លោក **មុំ សារិន** Mr. MOM Sarin សមាជិកា និងជានាយក HRCDO
7. អ្នកស្រី **ទីវ សារាយេត** Ms. TIV Sarayet សមាជិកា និងជាសហនាយិកា WMC
8. កញ្ញា **សយ សារា វឌ្ឍនី** Miss. SAY Sara Vathany សមាជិកា និងជានាយិកា CWCC
9. លោក **គីម សុវណ្ណ** Mr. KIM Sovann សមាជិក និងជានាយក VIGILANCE
10. នាយក LAC (NA)
11. នាយក KKKHRO (NA)
12. អ្នកស្រី **ពឹង យក់ហៀប** Ms. PEUNG Yok Hiep សមាជិកា ជាឥស្សរជន Dignitary
13. លោក **សឺន សែត** Mr. SEN Set សមាជិក ជាឥស្សរជន Dignitary


ស.ប្រ.ក.ព/លេខ ០៨/១០ គ.ប.ស.យ/អ.ក

# សេចក្តីប្រកាសព័ត៌មាន

## ស្តីពី

## លទ្ធផលវាយតម្លៃរបស់ម្ចាស់ឆ្នោតទៅលើការអនុវត្តន៍លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាព ក្នុងខេត្ត សៀមរាប

*ភ្នំពេញ, ថ្ងៃទី ១៨ ខែសីហា ឆ្នាំ ២០១០*

ម្ចាស់ឆ្នោតនៅខេត្តសៀមរាបប្រមាណ ៨៥នាក់ ក្នុងនោះមាន ស្រ្តី ៣៦នាក់ មកពីសហគមន៍ ដីធ្លី នេសាទ,,,,,,, អង្គការមិនមែនរដ្ឋាភិបាលនានា អាជីវករ/ពាណិជ្ជករ មន្ត្រីរាជការ សិស្ស/និស្សិត កសិករ ដែលមកពីស្រុកផ្សេងគ្នានិងក្រុងក្នុងខេត្តសៀមរាប បានបង្ហាញពីការពេញចិត្តច្រើនទៅលើការអនុវត្តន៏ការងាររបស់មន្ត្រីជាប់ឆ្នោត ក្នុងការអនុវត្តន៏លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពក្នុងខេត្តសៀមរាប បើទោះបីជាចំនុចនៃលក្ខខណ្ឌសន្ទស្សន៍ ស្ទើរតែទាំងអស់មិនត្រូវបានអនុវត្ត ឬអនុវត្តបានតិចតួចក៏ដោយ ។

បើទោះបីឆ្នាំកន្លងទៅ អ្នកតំណាងរាស្ត្រ និងក្រុមប្រឹក្សាខេត្ត (ទើបបង្កើតថ្មី) បានខិតខំជំរុញអោយរាជរដ្ឋាភិបាល (នីតិប្រតិបត្តិ) និងអាជ្ញាធរខេត្តដើម្បីអនុវត្តលក្ខខណ្ឌសន្ទស្សន៍នេះ ភាគច្រើនម្ចាស់ឆ្នោតមិនទាន់ពេញចិត្តការអនុវត្តន៍លក្ខខណ្ឌសន្ទស្សន៍ ព្រោះថាមានសន្ទស្សន៍សំខាន់មួយចំនួនដែលរាជរដ្ឋាភិបាល មន្ត្រីជាប់ឆ្នោត និងអាជ្ញាធរ មិនបានធ្វើទាល់តែសោះដូចជា ការផ្តល់ដីសម្បទានសង្គមកិច្ចដល់អ្នកក្រីក្រខ្វះដីពិតប្រាកដ ការតម្លើងប្រាក់បៀវត្សមន្ត្រីរាជការ កំណែទំរង់ប្រព័ន្ធតុលាការអោយមានភាពឯករាជ្យ អព្យាក្រិត និងយុត្តិធម៌, បន្ថយតំលៃអគ្គីសនី ការផ្តល់សំណងថ្លៃដីនៅស្រុកវ៉ារិន ជាពិសេស ការសុំអោយបញ្ឈប់ការដកហូតដីស្រែដោយអាជ្ញាធរអប្សរា ។

ក្នុងចំណោមលក្ខខណ្ឌសន្ទស្សន៍ទាំងអស់ មិនមានលក្ខខណ្ឌសន្ទស្សន៍ណាមួយដែលត្រូវបានម្ចាស់ឆ្នោតភាគច្រើនធ្វើការវាយតំលៃថាត្រូវបានអនុវត្តទាំងស្រុងឬអនុវត្តបានច្រើននោះទេ ។ ទោះបីយ៉ាងណាមាន លក្ខខណ្ឌសន្ទស្សន៍មួយចំនួនដូចជា ការលុបបំបាត់សេវាបំរើផ្លូវភេទ និងការលុបបំបាត់ ឧបករណ៏នេសាទខុសច្បាប់ ព្រមទាំងការបណ្តុះបណ្តាលបច្ចេកទេសកសិកម្ម ត្រូវបានម្ចាស់ឆ្នោតភាគច្រើន ធ្វើការវាយតំលៃថាកំពុងត្រូវបានអនុវត្តបានខ្លះៗ ។

អ្នកតំណាងរាស្ត្រ **កែ សុវណ្ណរតន៏** បានមានប្រសាសន៏ថា ក្នុងនាមជាអ្នកតំណាងអោយប្រជាពលរដ្ឋ លោកជំទាវនឹងខិតខំប្រឹងប្រែងជួយដល់ប្រជាពលរដ្ឋ ហើយក៏មានការគាំទ្រ និងប្តេជ្ញាបន្តអនុវត្តនូវអ្វីដែលជា

តំរូវការ របស់ប្រជាពលរដ្ឋ ។

ឯកឧត្តម **កៅ សោភ័ណ្ឌ** សមាជិកក្រុមប្រឹក្សាខេត្តសៀមរាប បានសន្យាថា នឹងដាក់ជូននូវអ្វីដែលប្រជាពលរដ្ឋបានលើកឡើងដល់គណៈអភិបាលខេត្ត ធ្វើការពិភាក្សាគ្នា និងគិតគូរវាល់បញ្ហាដែលមាន ។

លោក **លី សរិទ្ធ** នាយខុទ្ទកាល័យសាលាខេត្ត បានលើកឡើងពីការខិតខំប្រឹងប្រែងរបស់អាជ្ញាធរខេត្តក្នុងការបញ្ឈប់រាល់ការនាំចូលផលិតផលគ្មានគុណភាព ហើយក៏សុំអំពាវនាវដល់ប្រជាពលរដ្ឋអោយឈប់ប្រើប្រាស់ផលិតផលទាំងអស់នោះ ។

ការវាយតម្លៃនេះ ម្ចាស់ឆ្នោតធ្វើការផ្តល់ពិន្ទុទៅលើការបំពេញ/សម្រេចបានទៅលើចំនុចទីមួយៗដែលម្ចាស់ឆ្នោតបានធ្វើការទាមទារកាលពី ខែកក្កដា ឆ្នាំ២០០៩ ដោយឱ្យពិន្ទុ "ពិន្ទុ ១ សំរាប់ការមិនបានធ្វើទាល់តែសោះ ឬបានធ្វើតិចតួច(ច្រើនបំផុតត្រឹម ២០%)" "ពិន្ទុ ២ សំរាប់ការបានធ្វើខ្លះ (២១%-៤០%)" "ពិន្ទុ ៣ សំរាប់ការបានធ្វើមធ្យម ឬបានធ្វើពាក់កណ្តាល (៤១%-៦០%)" "ពិន្ទុ ៤ សំរាប់ការបានធ្វើច្រើន (៦១%-៨០%)" និង "ពិន្ទុ ៥ សំរាប់ការបានធ្វើស្ទើរតែទាំងស្រុង ឬបានធ្វើទាំងស្រុង (៨១%-១០០%)" ។

ជាលទ្ធផល ម្ចាស់ឆ្នោតប្រមាណ ៨៥នាក់ បានផ្តល់ពិន្ទុទៅលើការសម្រេចបានរបស់មន្ត្រីជាប់ឆ្នោតទៅលើចំនុចទីមួយៗ ដែលម្ចាស់ឆ្នោតបានកំណត់កាលពីឆ្នាំ២០០៩ ដូចខាងក្រោម:

| **លទ្ធផលនៃការវាយតម្លៃរបស់ម្ចាស់ឆ្នោតទៅលើការសម្រេចបាន របស់មន្ត្រីជាប់ឆ្នោតទៅលើចំនុចនីមួយៗនៃលក្ខខណ្ឌសន្ទស្សន៍នៃវិស័យអានិភាពនាំឲដប់នៅក្នុងខេត្តសៀមរាប** |
|---|
| ១) ជំរុញអោយរាជរដ្ឋាភិបាល និងសភាអនុម័តច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយអោយបានឆាប់រហ័សនៅដើមឆ្នាំ ២០១០ ។ ត្រូវអនុវត្តអោយបានត្រឹមត្រូវ [តាមច្បាប់កំណត់] ព្រមទាំងផ្សព្វផ្សាយដល់ប្រជាពលរដ្ឋអោយបានទូលំទូលាយទូទាំងប្រទេស ។<br>**ពិន្ទុ ១ (៤០%)** **ពិន្ទុ ២ (២៩%)** **ពិន្ទុ ៣ (២២%)** **ពិន្ទុ ៤ (៦%)** **ពិន្ទុ ៥ (៣%)** |
| ២) - ជួយផ្តល់វគ្គបណ្តុះបណ្តាលបច្ចេកទេសកសិកម្ម ៤ វគ្គក្នុងមួយឆ្នាំ ក្នុងមួយស្រុក អោយបាននៅគ្រប់ស្រុក ដើម្បីអោយទិន្នផល ពី១តោន ដល់ ៣ តោន ក្នុង១ ហិកតា ចាប់ពីដើមឆ្នាំ ២០១០ នេះតទៅ ។<br>- សុំផ្តល់ទុនកម្ចីដោយមានអត្រាការប្រាក់ទាប ប្រហែល ២ ភាគរយ ក្នុងមួយឆ្នាំ សំរាប់ការងារកសិកម្មនៅខេត្តសៀមរាប ចាប់ពីដើមឆ្នាំ ២០១០តទៅ ។<br>- ជួយរកទីផ្សារ បង្កើនតំលៃស្រូវ ១ គីឡូក្រាមយ៉ាងហោចណាស់ស្មើមួយភាគបីនៃតំលៃប្រេងសាំងក្នុង១លីត្រអោយបាន នៅដើមឆ្នាំ ២០១០ ។<br>**ពិន្ទុ ១ (១៨%)** **ពិន្ទុ ២ (៣៩%)** **ពិន្ទុ ៣ (៣០%)** **ពិន្ទុ ៤ (១២%)** **ពិន្ទុ ៥ (១%)** |
| ៣) ត្រូវទប់ស្កាត់ផលិតផលក្រៅស្រុក កុំអោយចូលមកខេត្តសៀមរាបមាន មាន់ ទា ត្រី ចាប់ពីឆ្នាំ២០១០ ។ លុបបំបាត់ឧបករណ៍នេសាទខុសច្បាប់អោយបាន [១០០ភាគរយ] ចាប់ពីខែ ១០ ឆ្នាំ២០០៩ តទៅ ។<br>**ពិន្ទុ ១ (៨%)** **ពិន្ទុ ២ (៤៤%)** **ពិន្ទុ ៣ (៣៨%)** **ពិន្ទុ ៤ (៨%)** **ពិន្ទុ ៥ (៣%)** |

៤) ផ្តល់ដីសម្បទានសង្គមកិច្ចដល់អ្នកក្រីក្រខ្វះដីពិតប្រាកដ មួយគ្រួសារអោយបាន ៣ ហិកតានៅខេត្តសៀមរាប អោយបាននៅដើមឆ្នាំ ២០១០ ។

**ពិន្ទុ ១ (៦៣%)** **ពិន្ទុ ២ (២៨%)** **ពិន្ទុ ៣ (៦%)** **ពិន្ទុ ៤ (៣%)** **ពិន្ទុ ៥ (0%)**

៥) សុំតម្លើងប្រាក់បៀវត្សរ៍ដល់មន្ត្រីរាជការព្រមទាំងកងកំលាំងប្រដាប់អាវុធអោយបានយ៉ាងតិច ១៥0 ដុល្លារក្នុងមួយខែឡើងទៅ ចាប់ពីឆ្នាំ ២០១០ តទៅ ។

**ពិន្ទុ ១ (៤១%)** **ពិន្ទុ ២ (៣៨%)** **ពិន្ទុ ៣ (១៥%)** **ពិន្ទុ ៤ (៣%)** **ពិន្ទុ ៥ (៣%)**

៦) កំណែទំរង់ប្រព័ន្ធតុលាការអោយមានភាពឯករាជ្យ អព្យាក្រិត និងយុត្តិធម៌ ១00ភាគរយ ចាប់ពីដើមឆ្នាំ ២០១០ ។

**ពិន្ទុ ១ (៦២%)** **ពិន្ទុ ២ (២៤%)** **ពិន្ទុ ៣ (៨%)** **ពិន្ទុ ៤ (៣%)** **ពិន្ទុ ៥ (៣%)**

៧) សុំអោយចាត់វិធានការតំលៃអគ្គីសនីនៅខេត្តសៀមរាបដោយ ១ គីឡូវ៉ាត់ ស្មើ ១ ភាគ ៤ នៃតំលៃប្រេងសាំង ចាប់ពីឆ្នាំ ២០១០ ។

**ពិន្ទុ ១ (៤0%)** **ពិន្ទុ ២ (៣៩%)** **ពិន្ទុ ៣ (១៦%)** **ពិន្ទុ ៤ (៣%)** **ពិន្ទុ ៥ (១%)**

៨) ផ្តល់សំណងថ្លៃដីនៅស្រុកវ៉ារិន្ទអោយបានសមរម្យ (តាមតំលៃទីផ្សារ) ដែលអាចទិញដីកន្លែងក្បែរៗនោះបានចាប់ពីឆ្នាំ ២០១០ និងបញ្ឈប់ការប្រើប្រាស់កំលាំងប្រដាប់អាវុធទៅគំរាមប្រជាពលរដ្ឋក្នុងខេត្តសៀមរាបចាប់ពីឆ្នាំ ២00៩ តទៅ ។

**ពិន្ទុ ១ (៤0%)** **ពិន្ទុ ២ (៣១%)** **ពិន្ទុ ៣ (១៩%)** **ពិន្ទុ ៤ (១0%)** **ពិន្ទុ ៥ (0%)**

៩) សុំអោយអាជ្ញាធរអប្សរាដោះដូរដីស្រែ (ដីកន្លែងថ្មីដែលនៅជិតភូមិប្រជាពលរដ្ឋ) អាចបង្កបង្កើនផលបានចាប់ពីឆ្នាំ ២០១០ ។ ស្នើសុំអោយបញ្ឈប់ការដកហូតដីស្រែដែលនៅសល់របស់ប្រជាពលរដ្ឋបន្តទៅទៀតនៅក្នុងតំបន់អប្សរា ចាប់ពីខែ សីហា ឆ្នាំ ២00៩តទៅ ។

**ពិន្ទុ ១ (៦៩%)** **ពិន្ទុ ២ (២១%)** **ពិន្ទុ ៣ (៦%)** **ពិន្ទុ ៤ (១%)** **ពិន្ទុ ៥ (៣%)**

១0) លុបបំបាត់សេវាបំរើផ្លូវភេទគ្រប់រូបភាពអោយបាន ១00ភាគរយ នៅក្នុងខេត្តសៀមរាប ចាប់ពីដើមឆ្នាំ ២០១០ ។

**ពិន្ទុ ១ (២0%)** **ពិន្ទុ ២ (៤១%)** **ពិន្ទុ ៣ (២៥%)** **ពិន្ទុ ៤ (១0%)** **ពិន្ទុ ៥ (៤%)**

១១) **ចំនុចរួមៈ តើអ្នកពេញចិត្តការអនុវត្តរបស់មន្ត្រីជាប់ឆ្នោតទៅលើលក្ខខណ្ឌសន្ទស្សន៍ទាំង១0 កម្រិតណា?**

☐១) មិនពេញចិត្តទាល់តែសោះ,☐២) ពេញចិត្តតិចតួច, ☐ ៣) ពេញចិត្តគួរសម, ☐៤) ពេញចិត្តច្រើន, ☐៥) ពេញចិត្តទាំងស្រុង

**ពិន្ទុ (៧%)** **ពិន្ទុ (២៥%)** **ពិន្ទុ (២៥%)** **ពិន្ទុ (២៨%)** **ពិន្ទុ ៥ (១៤%)**

ការវាយតម្លៃនេះ ត្រូវបានធ្វើឡើងដោយម្ចាស់ឆ្នោតក្នុងវេទិកាម្ចាស់ឆ្នោតដែលរៀបចំដោយគណៈកម្មាធិការ **ខុមហ្វ្រែល** នៅថ្ងៃទី ២៧ ខែកក្កដា ឆ្នាំ២០១០នៅខេត្តសៀមរាប ដោយមានកិច្ចសហការជាមួយសមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា (ADHOC), អង្គការសហការដើម្បីការអភិវឌ្ឍន៍នៅកម្ពុជា (PADEK) និងសម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ (LICADHO) ។

*សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង:*

- លោក **សុខ ពិន្ទុរឿ** អ្នកសម្របសម្រួលផ្នែកអង្កេតខុមហ្វ្រែល ទូរស័ព្ទ: 0៨៩ ៥២៥ ៤៤៦